ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ: ០២៥/២៥ ប.ស.ស

# សេចក្តីជូនដំណឹង

**បេឡាជាតិរបបសន្តិសុខសង្គម** មានកិត្តិយសសូមជម្រាបដល់លោកឧកញ៉ា លោក លោកស្រីជាម្ចាស់ ឬជានាយក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ឲ្យបានជ្រាបថា ចាប់តាំងពីការដាក់ឲ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ រហូតមកដល់បច្ចុប្បន្ននេះ **បេឡាជាតិរបបសន្តិសុខសង្គម** បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលបានមួយចំនួនធំហើយដែលមានឈ្មោះហៅថា" **មូលដ្ឋានសុខាភិបាលទទួលស្គាល់ដោយប.ស.ស** "(មានបញ្ជីឈ្មោះជូនភ្ជាប់មកជាមួយ) ។

បញ្ជីឈ្មោះ" **មូលដ្ឋានសុខាភិបាលទទួលស្គាល់ដោយប.ស.ស** " បានបញ្ជាក់ប្រាប់នូវអាសយដ្ឋាន លេខទូរស័ព្ទរថយន្តសង្គ្រោះបន្ទាន់(រថយន្តសាម៉ុយ) លេខទូរស័ព្ទទំនាក់ទំនង និងលេខទូរស័ព្ទភ្នាក់ងារប.ស.សប្រចាំការតាម"**មូលដ្ឋានសុខាភិបាលទទួលស្គាល់ដោយប.ស.ស**"។

ក្នុងករណីដែលកម្មករនិយោជិតរបស់ខ្លួនមានគ្រោះថ្នាក់ការងារ ដែលតម្រូវឲ្យប្រើប្រាស់សេវា" **មូលដ្ឋានសុខាភិបាលទទួលស្គាល់ដោយប.ស.ស** " ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជូនជនរងគ្រោះ បន្ទាប់មក ត្រូវផ្ញើរបាយការណ៍ហានិភ័យការងារមកបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

**បេឡាជាតិរបបសន្តិសុខសង្គម** មានក្តីសង្ឃឹមជឿជាក់ថា លោកឧកញ៉ា លោក លោកស្រីជាម្ចាស់ ឬជានាយក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថានទាំងអស់ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អត្រឹមត្រូវជាពុំខាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៥

**នាយក**

អ៊ុក_សមវិទ្យា